# ការវិវត្តន៍របស់ពងបោរ កើតលើអណ្តាត



ស្លាកស្នាមទើបចាប់មាននៅលើជើង



២-៣ ថ្ងៃក្រោយមកទៀត



ស្លាកស្នាមនៅលើដោះ



ស្លាកស្នាមនៅលើដៃរបស់មនុស្ស ឆ្លងជំងឺអុតក្តាម



# ជំងឺអុតក្តាម (FMD)

## ការការពារ :

- ការចាក់វ៉ាក់សាំងការពារមិនសូវមានប្រសិទ្ធិភាពលើជ្រូកទេ ប៉ុន្តែ វ៉ាក់សាំង ដែលគេធ្លាប់ប្រើគឺ ប្រភេទអូ (Type O) ដោយចាក់ វ៉ាក់សាំង ២ ដង/ឆ្នាំ ហើយធ្វើការចាក់ឡើងវិញ ប្រសិនបើនៅភូមិ ជិតនោះ មានផ្ទុះជំងឺនេះ។
- ជីវសុវត្ថិភាព : មិនងាយស្រួលទេ ព្រោះវាមានការវាតត្បាតខ្លាំង ប៉ុន្តែ ត្រូវតែរិតបន្តឹងលើការចូល ទស្សនកិច្ច ហើយអ្នកចូលទស្សនកិច្ច ត្រូវតែផ្លាស់ប្តូរសំលៀក បំពាក់ចេញ។

# ជំងឺអុតក្តាម (FMD)

## ➢ ការការពារ :

- ✓ ការចាក់វ៉ាក់សាំងការពារមិនសូវមានប្រសិទ្ធិភាពលើជ្រូកទេ ប៉ុន្តែ វ៉ាក់សាំង ដែលគេធ្លាប់ប្រើគឺ ប្រភេទអូ (Type O) ដោយចាក់វ៉ាក់សាំង ២ ដង/ឆ្នាំ ហើយធ្វើការចាក់ឡើងវិញ ប្រសិនបើនៅភូមិជិតនោះ មានផ្ទុះជំងឺនេះ។
- ✓ ជីវសុវត្ថិភាព : មិនងាយស្រួលទេ ព្រោះវាមានការរាតត្បាតខ្លាំង ប៉ុន្តែ ត្រូវតែរិតបន្តឹងលើការចូល ទស្សនកិច្ច ហើយអ្នកចូលទស្សនកិច្ច ត្រូវតែផ្លាស់ប្តូរសំលៀក បំពាក់ចេញ។

# ជំងឺសារទឹកជ្រូក

## ➢ បុព្វហេតុបង្កជំងឺ:

- ✓ ជាជំងឺឆ្លង ដែលបង្កឡើងដោយបាក់តេរី។ មេរោគឈ្មោះ ប៉ាស្ទឺរេលឡាម៉ុលតូស៊ីដា។
- ✓ ជំងឺនេះច្រើនកើតនៅលើជ្រូក គ្រប់ប្រភេទ ប៉ុន្តែកើតច្រើនបំផុតគឺ នៅលើជ្រូកអាយុ ចាប់ពី ២-៦ ខែ។
- ✓ ជំងឺនេះច្រើនកើតនៅដើម និងចុងរដូវ ភ្លៀង។

✓ មេរោគឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់រវាងជ្រូកឈឺ និងជ្រូកជា ឬឆ្លងដោយប្រយោល តាមរយៈមនុស្ស និង សត្វដទៃទៀតដែលមានជំងឺនេះ។

✓ ក្រៅពីនេះ ជំងឺក៏អាចឆ្លងពីធម្មជាតិបានដែរ ព្រោះមេរោគនៃជំងឺនេះរស់នៅក្នុងដី និងនៅ លើខ្លួនសត្វ ពេលណាសុខភាពសត្វចុះខ្សោយ ឬពេលណា មេរោគនៃជំងឺនេះជួបលក្ខណៈ អំណោយផល វារីកដុះដាលយ៉ាកឆាប់រហ័ស បង្កឱ្យមានជំងឺយ៉ាងធ្ងន់ធ្ងរ។

# ជំងឺសារទឹកជ្រូក

➤ រោគសញ្ញាៈ ចែកជាបីគឺ

✓ **កំរិតធ្ងន់:** ក្តៅខ្លាំង មិនស៊ីចំណី ងាប់រហ័ស ជួនកាលម្ចាស់អ្នកចិញ្ចឹម មិនទាំងដឹងថាជ្រូកឈឺផង ពេលខ្លះ គេឃើញជ្រូកដែលងាប់ដោយសារ ជំងឺនេះ មានហូរឈាមតាមច្រមុះ។

✓ **កំរិតមធ្យម:** រោគសញ្ញាច្បាស់បំផុតនោះគឺ វណាកស្អួត ហើមបំពង់ក ពិបាក ដកដង្ហើម ហេវហត់ ផតពោះ ហៀរសំបោរខាប់ ក្តៅពី ៤១-៤២ អង្សាសេ រួចហើយឃើញមានចំនុច ក្រហម ជួនកាលចំនុចក្រហមនេះផ្តុំគ្នាជាផ្ទាំងកន្លែង ស្បែកស្តើង ហើយ ៥-៦ ថ្ងៃ ក្រោយមកជ្រូកនិងងាប់។



# ជំងឺសារទឹកជ្រូក

## ➢ រោគសញ្ញា: ចែកជាបីកំរិត

✓ **កំរិតស្រាល:** ក្តៅ ៣៩-៤០ អង្សាសេ មិនសូវស៊ីចំណី វណាកស្អួត ហៀរសំបោរ ទល់លាមក ស្បែករបកទាំងផ្ទាំងៗ។ បើមិនថែទាំព្យាបាលឱ្យវាទេ ៤-៥ អាទិត្យក្រោយជ្រូកអាចងាប់ដោយសារហេវហត់ អស់កំលាំង។

# ជំងឺសារទឹកជ្រូក

## ➢ រោគវិនិច្ឆ័យ:

✓ **ក្នុងករិតធ្ងន់:** គ្រប់ភ្នាសស្តើងមានចេញឈាម រលាកសួត និងមាន ស្លេសនៅក្នុងបំពង់ក។

✓ **ករិតមធ្យម:** សួតរលាក ហើមពណ៌ស្វាយ រឹង ជួនកាលមានដក់ទឹក បេះដូងចេញឈាម ក្រពេញ ទងសួតហើម ចេញឈាម។

✓ **ករិតស្រាល:** សួតរលាកយ៉ាងខ្លាំង ជួនកាលមានខ្ទុះ។ នៅគ្រប់ករិត សុទ្ធតែមានហូរឈាមតាមស្បែក។



# ជំងឺសារទឹកជ្រូក

## ➢ ការព្យាបាល:

✓ ត្រូវព្យាបាលជាបន្ទាន់ ព្រោះជំងឺនេះបណ្តាលឱ្យជ្រូកងាប់ រហ័សណាស់ យើងអាចប្រើ ថ្នាំណាមួយក្នុង ចំណោមថ្នាំដូចខាងក្រោម:

- ស្រេបតូម៉ីស៊ី ៣-៤ ថ្ងៃ
- ប៉េនីស៊ីលីន ៣-៤ថ្ងៃ
- តេត្រាម៉ីស៊ីន ៣-៤ ថ្ងៃ
- ស៊ុលហ្វា ៣-៤ ថ្ងៃ

# ជំងឺសារទឹកជ្រូក

## វិធីការពារ

- ✓ ត្រូវធ្វើអនាម័យ  សំអាតទ្រុងជាប្រចាំ។
- ✓ ឱ្យជ្រូកស៊ីចំណីមានជីវជាតិគ្រប់គ្រាន់
- ✓ ខែភ្លៀងកុំលែងជ្រូកឱ្យចេញក្រៅទ្រុង
- ✓ ត្រូវលាងបន្លែឱ្យស្អាតមុនឱ្យជ្រូកស៊ី។
- ✓ បំបែកជ្រូកឈឺចេញពីជ្រូកជា
- ✓ ចាក់ថ្នាំការពារជំងឺសារទឹក  ចាក់សើរស្បែក។

# ជម្ងឺសាល់ម៉ូណេឡូស

## បុព្វហេតុបង្កជំងឺ

ជម្ងឺនេះកើតលើជ្រូកគ្រប់ប្រភេទ  ពិសេសលើកូនជ្រូក។

ជម្ងឺនេះបង្កឡើងដោយវីរុសបានធ្វើអោយរលាកពោះវៀនធ្ងន់ធ្ងរ។

# ជម្ងឺសាល់ម៉ូណែឡូស

➢ **រោគសញ្ញា**

-មិនស៊ីចំណី ក្អួត និង រាគរូសយ៉ាងខ្លាំង

-រាគរូសជាប្រចាំ ស្រកទំងន់ ផឹកទឹកច្រើន

-លាមកពណ៌ស ជួនកាលបៃតងស្លឹកឈើ

-កូនជ្រូកឈឺនៅតែក្បែរស្នូកទឹក ហើយអាចស្លាប់ក្នុងរយៈពេល១អាទិត្យបន្ទាប់មានរោគសញ្ញាជាលើកដំបូក។ ករណីខ្លះកូនជ្រូកអាចស្លាប់ក្នុងរយៈពេលមិនដល់៤៨ម៉ោង។ អត្រាងាប់អាចមានដល់១០០ %ចំពោះកូនជ្រូកអាយុក្រោម១អាទិត្យ។



# ជម្ងឺសាល់ម៉ូណែឡូស

➢ **ស្ថានភាព:** កូនជ្រូកឈឺឃ្យូរថ្ងៃ ក្នុងក្រពះទទេស្អាត ចំណែកកូនជ្រូកឈឺភ្លាមងាប់ភ្លាមក្នុងក្រពះពេញដោយទឹកដោះ។ ប្រដាប់រំលាយអាហារមានស្នាមដំបៅ។

➢ **រោគវិនិច្ឆ័យ:** សំគាល់បានដោយសារ

-ឆ្លងរាលដាលលឿន

-អត្រាងាប់ខ្ពស់

# ជម្ងឺសាល់ម៉ូណេឡូស

**➢ ការព្យាបាល**

-មិនទាន់មានថ្នាំណាអាចព្យាបាលបានគប់ប្រសើរទេ ប៉ុន្តែថ្នាំអង់ទីប៊ីយូទិកមួយចំនួនដូចជា: អូរីអូមីស៊ីន និង តេរ៉ាមីស៊ីន ដែលប្រើព្យាបាលកូនជ្រូកដើម្បីពន្យាថ្ងៃងាប់ប៉ុណ្ណោះ ។

-ហ្កានីដេន ស៊ុលហ្វាធីយ៉ាស៊ូល ស៊ុលហ្វាមេរ៉ាស៊ីន រយៈពេល៣-៤ថ្ងៃ

-ចាក់សេរ៉ូម ផ្អែម រឺ សេរ៉ូមប្រៃ អោយស៊ីចំណីសំបូរជីវជាតិ រឺអោយផឹក ប៉ូលីវីតាមីន ។

**➢ ការការពារ:** ត្រូវចាក់ថ្នាំការពារតាមការណែនាំរបស់បសុពេទ្យ ។



# ជម្ងឺបរ៉ាស៊ីត

**១_បរ៉ាសិតខាងក្នុង:** ព្រូនមូល និងព្រូនសំប៉ែត ។ រស់នៅខាងក្នុងសារពាង្គកាយរបស់ជ្រូកដូចជា ភ្នែក ពោះវៀន និង ប្រព័ន្ធរំលាយអាហារ ។




# ជម្ងឺបរ៉ាស៊ីត

២_បរ៉ាសិតខាងក្រៅ៖ ចៃ អង្កែ កមរមាស់ ដែលរស់ នៅក្រៅ សារពាង្គកាយជ្រូក (នៅក្នុងរោម ស្បែក) ។